**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០០៧ សរណន

ថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១

# សារាចរណែនាំ

## ស្តីពី

## ការកំណត់លក្ខខណ្ឌបិទអាជីវកម្ម ឬព្យួរអាជ្ញាបណ្ណទេសចរណ៍ ចំពោះអាជីវកម្មសេវាកម្មទេសចរណ៍ស្របតាមខ្លឹមសារមាត្រា៥ មាត្រា៦ មាត្រា១០ និងមាត្រា១១ នៃច្បាប់ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត

ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការចូលរួមអនុវត្តច្បាប់ស្តីពី **"វិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត"** និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមានផ្សេងទៀត ក្រសួងទេសចរណ៍ សូមណែនាំអំពីលក្ខខណ្ឌបិទអាជីវកម្ម ឬព្យួរអាជ្ញាបណ្ណទេសចរណ៍ចំពោះអាជីវកម្មសេវាកម្មទេសចរណ៍ ស្របតាមខ្លឹមសារមាត្រា៥ មាត្រា៦ មាត្រា១០ និងមាត្រា១១ នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេង ទៀតដូចខាងក្រោម៖

១). និយមន័យ ទណ្ឌកម្មរដ្ឋបាលដោយ **"បិទអាជីវកម្ម"** ឬ **"ព្យួរអាជ្ញាបណ្ណទេសចរណ៍"**៖

១.១. ទណ្ឌកម្មដោយការសម្រេច **"បិទអាជីវកម្ម"** ដោយមូលហេតុមិនអនុវត្តតាមវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលចេញដោយក្រសួងទេសចរណ៍ សំដៅដល់ការសម្រេចបិទអាជីវកម្មជាអចិន្ត្រៃយ៍ និងដកហូតអាជ្ញាបណ្ណទេសចរណ៍សុពលភាព។ ការសម្រេចបិទអាជីវកម្មមិននាំទៅរកការបិទនិងហ៊ុំព័ទ្ធទីតាំងឡើយ លើកលែងមានការសម្រេចដោយឡែករបស់រដ្ឋបាលរាជធានី ខេត្ត។ ការសម្រេចបិទអាជីវកម្ម ត្រូវដាក់ចេញអមជាមួយរយៈពេលដាក់បំរាមមិនឱ្យអាជីវកម្មនោះ និង/ឬអ្នកឈរឈ្មោះលើអាជ្ញាបណ្ណទេសចរណ៍នោះធ្វើប្រតិបត្តិការក្នុងវិស័យទេសចរណ៍ក្នុងរយៈពេលកំណត់ណាមួយចន្លោះពី **០១(មួយ)ឆ្នាំ** ដល់ **០៥(ប្រាំ)ឆ្នាំ** គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចបិទអាជីវកម្មនោះ។ អាជីវកម្មដែលរងការសម្រេច **"បិទអាជីវកម្ម"** ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណទេសចរណ៍ថ្មីឡើងវិញ ក្រោយរយៈពេលហាមឃាត់បានបញ្ចប់។

១.២. ទណ្ឌកម្មដោយការសម្រេច **"ព្យួរអាជ្ញាបណ្ណទេសចរណ៍"** ដោយមូលហេតុមិនអនុវត្តតាមវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលចេញដោយក្រសួងទេសចរណ៍ សំដៅដល់ការសម្រេចផ្អាកប្រតិបត្តិការអាជីវកម្ម ដែលមានអាជ្ញាបណ្ណទេសចរណ៍សុពលភាពក្នុងរយៈពេលកំណត់ណាមួយដែលមានថេរវេលាក្នុងរយៈពេលសុពលភាពរបស់អាជ្ញាបណ្ណ ដែលសម្រេចឱ្យព្យួរនោះ។ ការសម្រេចព្យួរអាជ្ញាបណ្ណទេសចរណ៍មិននាំទៅរកការបិទនិងហ៊ុំព័ទ្ធទីតាំងឡើយ លើកលែងមានការសម្រេចដោយឡែករបស់រដ្ឋបាលរាជធានីខេត្ត។ អាជីវកម្មត្រូវស្នើសុំបើកដំណើរការឡើងវិញមកក្រសួងទេសចរណ៍ ឬបន្តសុពលភាពអាជ្ញាបណ្ណទេសចរណ៍ ក្រោយរយៈពេលកំណត់ឱ្យផ្អាកប្រតិបត្តិការត្រូវបានបញ្ចប់។

វិថីលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

២). ក្រសួងទេសចរណ៍ មានសិទ្ធិសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដោយការ **"បិទអាជីវកម្ម"** ចំពោះករណីដូចខាងក្រោម៖

២.១. លបលួចតាមគ្រប់មធ្យោបាយ ឬគ្រប់រូបភាពផ្សេងៗ បន្តប្រតិបត្តិការសកម្មភាពអាជីវកម្មរបស់ខ្លួន នៅក្នុងអំលុងពេលដែលរាជរដ្ឋាភិបាល ឬក្រសួងទេសចរណ៍បានសម្រេចឱ្យផ្អាកសកម្មភាព

២.២. រារាំងដល់ការអនុវត្តវិធានការរដ្ឋបាលដែលបានសម្រេចដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច។

៣). ក្រសួងទេសចរណ៍មានសិទ្ធិសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដោយការ **"ព្យួរអាជ្ញាបណ្ណទេសចរណ៍"** ចំពោះករណីដូចខាងក្រោម៖

៣.១. មិនអនុវត្តត្រឹមត្រូវតាមវិធានសុវត្ថិភាពទេសចរណ៍ដូចមានកំណត់ក្នុងប្រកាសលេខ ០៨១ ប្រក. ប្រកាសលេខ ០៨២ ប្រក. ប្រកាសលេខ ០៨៣ ប្រក. ប្រកាសលេខ ០៨៤ ប្រក. ប្រកាសលេខ ០៨៥ ប្រក. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ និងប្រកាសលេខ ០៩៥ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០២០

៣.២. មិនសហការចងក្រង រក្សាទុកព័ត៌មានរបស់ភ្ញៀវតាមការណែនាំរបស់ក្រសួងទេសចរណ៍ដូចមានកំណត់ក្នុងសារាចរណែនាំលេខ ០០១ សរណន. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១

៣.៣. មិនសហការផ្តល់រាល់ព័ត៌មានរបស់ភ្ញៀវ ឬរបស់បុគ្គលិក ឬរបស់អាជីវកម្មតាមការស្នើសុំរបស់ក្រសួងទេសចរណ៍

៤). នីតិវិធីអំពីការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដោយការ **"បិទអាជីវកម្ម"** ឬ **"ព្យួរអាជ្ញាបណ្ណទេសចរណ៍"**៖

៤.១. ក្រសួងទេសចរណ៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនសិន មុននឹងឈានដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាល។

៤.២. ការអនុវត្តទណ្ឌកម្មរដ្ឋបាល អាចធ្វើនៅថ្ងៃទី០៣(បី) ចាប់រាប់ពីថ្ងៃដែលការជូនដំណឹងជាលាយលក្ខណ៍អក្សរត្រូវបានផ្សព្វផ្សាយជាសាធារណៈ ក្នុងករណីដែលអាជីវកម្មបានបង្កការលំបាក មិនសម្រួលដល់ការជូនដំណឹងដោយចំពោះ។

៤.៣. ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដោយការ **"បិទអាជីវកម្ម"** ត្រូវសម្រេចដោយ **រដ្ឋមន្ត្រីក្រសួងទេសចរណ៍** និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងដោយចំពោះ ក្រោមទម្រង់ជាសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល។ សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពអនុវត្តភ្លាមៗ និងត្រូវអនុវត្តដោយ អគ្គាធិការដ្ឋាននៃក្រសួងទេសចរណ៍ សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤.៤. ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដោយការ **"ព្យួរអាជ្ញាបណ្ណទេសចរណ៍"** ត្រូវសម្រេចដោយអគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងដោយចំពោះ ក្រោមទម្រង់ជាសេចក្តីសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល។ សេចក្តីសម្រេចនេះមានប្រសិទ្ធិភាពអនុវត្តភ្លាមៗ និងត្រូវអនុវត្តដោយនាយកដ្ឋានជំនាញពាក់ព័ន្ធសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

៥). ក្នុងករណីដែលមានភស្តុតាងបង្ហាញថា អាជីវកម្មមិនសហការប្តឹង ឬរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចពីសកម្មភាពរបស់ភ្ញៀវទេសចរ ឬសកម្មភាពផ្សេងៗដែលកើតមកលើភ្ញៀវទេសចរនូវសកម្មភាពដែលច្បាប់ហាមឃាត់ អាជីវកម្មត្រូវរងការពិន័យអន្តរការណ៍ជាប្រាក់ចំនួន ០១(មួយ)លានរៀល ស្របតាមចំណុចទី៤ នៃឧបសម្ព័ន្ធ៣ ប្រកាសអន្តរក្រសួងលេខ ១៦០ សហវ.ប្រក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

៦). ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលក្នុងស្មារតីសារាចរណែនាំនេះ មិននាំដល់ការរួចផុតកាតព្វកិច្ចនិងការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌ ឬការអនុវត្តទោស ឬពិន័យអន្តរការណ៍ដែលមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានផ្សេងទៀតឡើយ។

៧). ទោសប្បញ្ញត្តិនៃការអនុវត្តបិទអាជីវកម្ម និងព្យួរអាជ្ញាបណ្ណនេះ គឺជាការអនុវត្តដាច់ដោយឡែកពីសិទ្ធិ និងអំណាចផ្សេងៗទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានសិទ្ធិក្នុងការបិទ ឬហាមប្រាមអាជីវកម្មទាំងឡាយណា ដែលរកឃើញថាមានការប៉ះពាល់ ឬអាចបង្កឱ្យមានហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈក្នុងការឆ្លងរាលដាលជំងឺកូវីដ-១៩។

៨). ទទួលបានសារាចរណែនាំនេះ រដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំសេចក្តីណែនាំដោយឡែកដើម្បីគ្រប់គ្រង និងអនុវត្តការបិទអាជីវកម្ម ការព្យួរអាជ្ញាបណ្ណចំពោះរាល់អាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ដែលស្ថិតនៅក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់រដ្ឋបាលរាជធានី ខេត្តសាមីរៀងៗខ្លួន ដោយប្បញ្ញត្តិនៃការណែនាំរបស់រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុលោមតាមសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ សូម **ម្ចាស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍** ត្រូវចាត់ចែងពង្រឹងការអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីបញ្ចប់ជំងឺកូវីដ-១៩។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**កន្លែងទទួលៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ១៩
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- លេខាធិការដ្ឋាននៃ គ.ជ.អ.ប.
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ